# រដ្ឋាភិបាលទាំងបីថ្នាក់

ប្រទេសអូស្ត្រាលីគឺជាប្រទេសកាន់របបលទ្ធិសភាប្រជាធិបតេយ្យ ដែលប្រជាជនមានសិទ្ធិបោះឆ្នោតជ្រើសរើសអ្នកតំណាងរបស់ខ្លួនដើម្បីនិយាយ ហើយធ្វើសេចក្ដីសំរេចជំនួសគេ។

ពលរដ្ឋអូស្ត្រាលីបោះឆ្នោតជ្រើសរើសអ្នកតំណាងសំរាប់ថ្នាក់រដ្ឋាភិបាលនីមួយនៃរដ្ឋាភិបាលទាំងបីថ្នាក់ – គឺរដ្ឋាភិបាលសហព័ន្ធ រដ្ឋាភិបាលប្រចាំរដ្ឋ ឬរដ្ឋាភិបាលប្រចាំដែនដី ហើយនិងរដ្ឋាភិបាលប្រចាំតំបន់។

## រដ្ឋាភិបាលសហព័ន្ធ

អង្គការធ្វើសេចក្ដីសំរេចរបស់រដ្ឋាភិបាលសហព័ន្ធគឺសភាសហព័ន្ធ ដែលមានសភាពីរ – គឺសភាតំណាងរាស្ត្រ (House of Representatives) និងព្រឹទ្ធសភា (Senate)។

តំណាងរាស្ត្រដែលគេជ្រើសរើសឲ្យនៅសភាតំណាងរាស្ត្រ ត្រូវគេហៅថាសមាជិកសភាតំណាងរាស្ត្រ (Members of the House of Representatives)។ មានសមាជិកសភាតំណាងរាស្ត្រទាំងអស់ចំនួន១៥០នាក់ ហើយសមាជិកនីមួយៗជាអ្នកតំណាងមណ្ឌលបោះឆ្នោតដោយឡែកៗពីគ្នា។

អ្នកដឹកនាំរដ្ឋាភិបាលសហព័ន្ធត្រូវគេហៅថានាយករដ្ឋមន្ត្រី (Prime Minister)។

ការបោះឆ្នោតសហព័ន្ធត្រូវតែធ្វើឡើងរៀងរាល់បីឆ្នាំម្ដង ដោយហេតុថារដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលីកំណត់នូវរយៈពេលកាន់តំណែងសំរាប់សមាជិកសភាតំណាងរាស្ត្រ។

អ្នកតំណាងរាស្ត្រដែលគេជ្រើសរើសឲ្យនៅព្រឹទ្ធសភា ត្រូវគេហៅថាសមាជិកព្រឹទ្ធសភា ហើយគេជាអ្នកតំណាងរដ្ឋ ឬដែនដី។ មានសមាជិកព្រឹទ្ធសភាទាំងអស់ចំនួន១២នាក់សំរាប់រដ្ឋនីមួយៗ ហើយមានសមាជិកព្រឹទ្ធសភាទាំងអស់ចំនួន២នាក់សំរាប់ដែនដីនីមួយៗ។ សមាជិកព្រឹទ្ធសភាប្រចាំរដ្ឋត្រូវបានជ្រើសរើសសំរាប់រយៈពេលកាន់តំណែង៦ឆ្នាំ ចំពោះសមាជិកព្រឹទ្ធសភាប្រចាំដែនដីវិញត្រូវបានជ្រើសរើសសំរាប់រយៈពេលកាន់តំណែង៣ឆ្នាំ។

ការទទួលខុសត្រូវរបស់រដ្ឋាភិបាលសហព័ន្ធមានរួមទាំងៈ កិច្ចការបរទេស កិច្ចការសង្គមកិច្ច ផ្នែកទំនាក់ឧស្សាហកម្ម ពាណិជ្ជកម្ម អន្តោប្រវេសន៍ រូបិយវត្ថុ ហើយនិងការពារប្រទេស។

## រដ្ឋាភិបាលប្រចាំរដ្ឋ និងរដ្ឋាភិបាលប្រចាំដែនដី

អង្គការធ្វើសេចក្តីសំរេចរបស់រដ្ឋាភិបាលប្រចាំរដ្ឋ គឺរដ្ឋសភាដែលប្រជុំនៅក្នុងសភាតំណាងរាស្ត្រនៃរដ្ឋដោយឡែកនីមួយៗ។ រដ្ឋសភានីមួយៗ លើកលែងតែរដ្ឋសភាឃ្វីនស្លែន (Queensland Parliament) គឺមានរដ្ឋសភា២។

អ្នកតំណាងរាស្ត្រដែលគេជ្រើសរើសឲ្យទៅរដ្ឋសភា ជាទូទៅត្រូវគេហៅថា "សមាជិក" - សមាជិកសភានីតិបញ្ញត្តិ (Members of the Legislative Assembly/MLA) ឬសមាជិកសភាជាន់ទាប (Members of the House of Assembly/MHA) ឬសមាជិកទីប្រឹក្សានីតិបញ្ញត្តិ (Members of the Legislative Council/MLC)។ អ្នកដឹកនាំរដ្ឋាភិបាលប្រចាំរដ្ឋត្រូវគេហៅថាអភិបាលរដ្ឋ (Premier)។

ដែនដីអូស្ត្រាលីខាងជើង (Northern Territory/NT) និងដែនដីរដ្ឋធានីអូស្ត្រាលី (Australian Capital Territory/ACT) មានរបៀបរៀបចំរដ្ឋាភិបាលផ្សេងៗពីគ្នា។ សភាដែនដីនីមួយៗមានសភាមួយហៅថាសភានីតិបញ្ញត្តិ (Legislative Assembly)។ អ្នកដឹកនាំដែនដីនីមួយៗត្រូវគេហៅថាប្រមុខរដ្ឋមន្ត្រី (Chief Minister)។

ការទទួលខុសត្រូវរបស់រដ្ឋាភិបាលប្រចាំរដ្ឋ និងរដ្ឋាភិបាលប្រចាំដែនដីមានរួមទាំង: យុត្តិធម៌ កិច្ចការអ្នកប្រើប្រាស់ សុខភាព ការអប់រំ រុក្ខាប្រមាញ់ គមនាគមន៍សាធារណៈ ហើយនិងផ្លូវថ្នល់សំខាន់ៗ។

## រដ្ឋាភិបាលប្រចាតំបន់

អង្គការធ្វើសេចក្តីសំរេចរបស់រដ្ឋាភិបាលប្រចាំតំបន់ ជាទូទៅត្រូវគេហៅថាសាលាក្រុង (city council) ឬក្រុង (shire council)។ សាលាក្រុងបានបង្កើតឡើងដោយរដ្ឋាភិបាលប្រចាំរដ្ឋដើម្បីឲ្យមើលខុសត្រូវលើសេចក្តីត្រូវការជាក់លាក់របស់សាលាក្រុង ឬសហគមន៍ប្រចាំតំបន់។ អ្នកតំណាងរាស្ត្រដែលបង្កើតជាក្រុមប្រឹក្សាត្រូវគេហៅថាភូឈ្មួយក្រុង (aldermen) ឬសមាជិកទីប្រឹក្សាសាលាក្រុង (councillors)។ អ្នកដឹកនាំសាលាក្រុងគឺជាអភិបាលក្រុង (mayor) ឬប្រធានសាលាក្រុង (shire president)។

ការទទួលខុសត្រូវរបស់រដ្ឋាភិបាលប្រចាំតំបន់មានរួមទាំង: ការមើលថែផ្លូវថ្នល់ប្រចាំតំបន់ ការប្រមូលសំរាម បទបញ្ជាសាងសង់ និងការបែងចែកទឹកដីជាបន្តទៀត សុខភាពសាធារណៈ ហើយនិងគ្រឿងបរិក្ខាកម្សាន្តទាំងឡាយមានដូចជាអាងហែលទឹកជាដើម។

ព័ត៌មានបន្ថែមទៀតអំពីដំណើរការបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត ហើយនិងការបោះឆ្នោតអាចទទួលយកបានពីគេហទំព័ររបស់ AEC គឺ www.aec.gov.au ឬដោយទូរស័ព្ទលេខ 13 23 26។

ដើម្បីទទួលយកព័ត៌មានបន្ថែមទៀតជាភាសាខ្មែរ សូមទូរស័ព្ទលេខ 1300 720 148។